សួស្តី នៅក្នុងរូបភាពនេះគឺយើងនឹងនិយាយអំពីការចូលគេង។ អញ្ចឹងជាទូទៅមនុស្សយើង ក្រោយពីពេលដែលធ្វើការ ឬក៏ក្រោយពីពេលដែលយើងមកពីខាងក្រៅនឿយហត់ អញ្ចឹងជាទូទៅយើងតែងតែចូលគេងនៅពេលយប់។ ជាធម្មតាគឺយើងចូលគេងនៅពេលយប់ ហើយក្រោកនៅពេលព្រឹក ដើម្បីទៅធ្វើការ ឬក៏បំពេញការងារ ឬក៏ទៅរៀន ឬក៏ទៅធ្វើការសិក្សានានា។

អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ១ នៅក្នុងរូបភាពទី ១ យើងឃើញមានក្មេងប្រុសម្នាក់ ដែលក្មេងប្រុសម្នាក់ហ្នឹង មើលទៅគាត់នៅក្មេងដែរទេ ប្រហែលជាគាត់មានអាយុប្រហែលជាម្ភៃឆ្នាំ ដែលយើងឃើញគាត់ពាក់អាវដៃខ្លីពណ៌ខៀវ ដែលអាវរបស់គាត់មានកូនហោប៉ៅតូចមួយនៅខាងឆ្វេង។ អញ្ចឹងនៅលើទ្រូងខាងឆ្វេង គឺមានកូនហោប៉ៅតូចមួយ ដែលកូនហោប៉ៅនោះគឺសម្រាប់ដាក់លុយ ឬក៏ដាក់សម្ភារៈផ្សេងៗ ដែលគាត់ចង់យកតាមខ្លួន អញ្ចឹងរបស់តូចៗ ដូចជាលុយ ដូចជាប៊ិច ឬក៏កូនសៀវភៅផ្សេងៗហ្នឹង គាត់អាចដាក់តាមខ្លួនបាន ដោយគាត់ដាក់ចូលទៅក្នុងកូនហោប៉ៅតូចដែលនៅលើអាវខាងស្តាំ ឬក៏ ឬក៏ហោប៉ៅអាវដែលនៅខាងស្តាំ នៅលើទ្រូងខាងស្តាំ។ អញ្ចឹងរូបភាពទី ១ នេះ យើងឃើញក្មេងប្រុសម្នាក់ហ្នឹង គាត់កំពុងតែស្ងាប ដោយគាត់ស្ងាបដោយហាមាត់ធំៗ និងបិទភ្នែក ហើយលើកដៃម្ខាងឡើងទៅលើ ដៃម្ខាងទៀតគាត់យកមកខ្ទប់មាត់ គឺគាត់កំពុងតែពត់ខ្លួននិងស្ងាប ព្រោះប្រហែលជាគាត់នឿយហត់ ដោយសារតែគាត់ទើបតែមកពីក្រៅ ឬក៏ដោយសារតែគាត់អស់កម្លាំង ដោយសារតែគាត់ធ្វើការ ឬក៏គាត់ដើរលេងហត់ អញ្ចឹងគាត់អស់កម្លាំង។ ដូច្នេះហើយគាត់ក៏បានពត់ខ្លួនហើយស្ងាប ដែលជាកាយវិការមួយ បានន័យថាយើងកំពុងតែងុយគេង។ អញ្ចឹងជាទូទៅនៅពេលដែលយើងងុយគេង ឬក៏អស់កម្លាំង យើងតែងតែស្ងាប ហើយនៅពេលដែលយើងស្ងាប គឺយើងពត់ខ្លួន ដើម្បីឲ្យយើងបានស្រួលខ្លួនបន្តិច អញ្ចឹងនៅពេលដែលយើងពត់ខ្លួន គឺយើងមានអារម្មណ៍ថាស្រួលខ្លួន។ ដែលជាក់ស្តែងយើងឃើញក្នុងរូបភាពនេះគឺក្មេងប្រុសម្នាក់នោះ គាត់បានលើកដៃឆ្វេងរបស់គាត់ឡើងទៅលើត្រង់ខ្ពស់ ហើយគាត់ក្តាប់ដៃរបស់គាត់ អញ្ចឹងម្រាមដៃរបស់គាត់ក្តាប់ចូលគ្នា ហើយដៃម្ខាងទៀតរបស់គាត់ ដែលជាដៃខាងស្តាំ គាត់យកមកខ្ទប់មាត់ដែលគាត់កំពុងតែស្ងាប។ អញ្ចឹងគាត់កំពុងតែស្ងាបដោយហាមាត់ធំៗ ហើយយកដៃរបស់គាត់មកខ្ទប់មាត់របស់គាត់ ដោយកាយវិការពត់ខ្លួន ព្រោះតែគាត់អស់កម្លាំង និងងងុយគេងជាខ្លាំង។

បន្ទាប់មកទៀតរូបភាពទី ២ នៅក្នុងរូបភាពទី ២ យើងឃើញក្មេងប្រុសម្នាក់នោះ គាត់ក៏បាន បន្ទាប់ពីគាត់ពត់ខ្លួនរួចរាល់ហើយ អញ្ចឹងគាត់ស្ងាប គាត់អស់កម្លាំង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ដោយសារតែគាត់មកពីក្រៅនឿយហត់ ឬក៏មកពីធ្វើការនឿយហត់ ឬក៏មកពីរៀននឿយហត់ អញ្ចឹងគាត់ក៏បានអស់កម្លាំង ហើយក៏បានគិតទៅដល់គ្រែគេងរបស់គាត់។ អញ្ចឹងនៅក្នុងរូបភាពនេះ គឺគាត់កំពុងតែដើរសំដៅទៅក្នុងបន្ទប់គេងរបស់គាត់ ដោយយើងឃើញគាត់ដើរបណ្ដើរ គិតទៅរកគ្រែគេងបណ្ដើរ។ អញ្ចឹងបានន័យថាក្មេងប្រុសម្នាក់នេះ ដែលនៅក្នុងរូបភាពទី ២ គឺគាត់កំពុងតែដើរសំដៅទៅបន្ទប់គេង ដើម្បីចូលគេងនៅក្នុងបន្ទប់របស់គាត់ ដោយយើងឃើញគាត់កំពុងតែគិតទៅដល់គ្រែគេងមួយ ដែលគ្រែគេងដែលគាត់កំពុងតែគិតនោះ យើងឃើញមានពូកមួយដែលនៅពីលើគ្រែ អញ្ចឹងគ្រែគេងគឺមានជើងបួន ហើយមានរាងទ្រវែង គឺខុសពីតុបន្តិច ដោយសារតែតុគឺមានខ្លះរាងជ្រុង ខ្លះរាងមូល ហើយខ្ពស់ជាងគ្រែ ប៉ុន្តែគ្រែគឺវែង ដោយសារសម្រាប់យើងគេង។ អញ្ចឹងគ្រែមានជើងបួន ហើយនៅលើគ្រែគឺ ជាទូទៅគឺយើងដាក់ពូក ហើយនិងដាក់ខ្នើយ ក៏ប៉ុន្តែបើសិនជានៅក្នុងស្រែ នៅតាមទីជនបទ ឬក៏ស្រុកស្រែចំការ ពេលខ្លះគាត់អត់មានពូកទេ អញ្ចឹងគាត់គេងគ្រែដោយប្រើកន្ទេល ឬក៏កម្រាល អញ្ចឹងគាត់គ្រាន់តែក្រាលកន្ទេល ក៏គាត់អាចគេងបានដែរ ប៉ុន្តែវាអត់ទន់ដូចពូកនោះទេ អញ្ចឹងជាទូទៅនៅទីក្រុង គឺយើងគេងដោយដាក់ក្រាលដោយសារពូក អញ្ចឹងបន្ទាប់ពីយើងដាក់គ្រែហើយ គឺយើងដាក់ពូកនៅលើគ្រែ ចំណែកឯនៅជនបទ គឺយើងដាក់គ្រែហើយ គឺយើងក្រាលកន្ទេលនៅលើគ្រែ ហើយគេងតែម្ដង អញ្ចឹងការគេងលើកន្ទេល គឺអត់សូវស្រួលខ្លួនទេដោយសារវារឹង អញ្ចឹងវាអាចធ្វើឲ្យយើងឈឺខ្លួន ក៏ប៉ុន្តែបើយើងគេងនៅលើពូក គឺវាទន់ស្រួល អញ្ចឹងយើងអាចគេងលក់ស្រួលបាន។ ដែលជាក់ស្ដែងយើងឃើញគ្រែគេងរបស់ក្មេងប្រុសម្នាក់នេះ ដែលកំពុងតែគិត គឺយើងឃើញមានពូកមួយនៅលើគ្រែ ហើយមានខ្នើយកើយមួយនៅលើគ្រែនោះផងដែរ។ អញ្ចឹងគាត់កំពុងតែដើរសំដៅទៅបន្ទប់គេងរបស់គាត់ ដោយដើរបណ្ដើរ គិតអំពីគ្រែគេងរបស់គាត់បណ្ដើរ។

បន្ទាប់មកទៀតរូបភាពទី ៣ រូបភាពទី ៣ យើងឃើញថា បន្ទាប់ពីគាត់ដើរមកដល់បន្ទប់គេងរបស់គាត់ហើយ គាត់អត់បានចូលទៅគ្រែគេងគាត់ភ្លាមនោះទេ អញ្ចឹងគាត់អត់ទាន់ចូលគេងភ្លាមនោះទេ ដោយគាត់ដើរសំដៅមករកបន្ទប់ទឹករបស់គាត់សិន។ អញ្ចឹងជាធម្មតាយើងឃើញក្មេងប្រុសម្នាក់នេះ គឺគាត់ពាក់អាវខៀវដដែល គឺគាត់អត់ទាន់ផ្លាស់ខោអាវទេ ហើយគាត់ស្លៀកខោជើងវែងពណ៌ខ្មៅ ប៉ុន្តែយើងអត់ឃើញគាត់ពាក់ស្បែកជើងនោះទេ។ អញ្ចឹងជាទូទៅ នៅពេលដែលយើងចូលដល់ក្នុងផ្ទះ យើងតែងតែដោះស្បែកជើង ឬក៏ទ្រនាប់ជើងចេញ ហើយជាពិសេសនៅពេលដែលយើងមកដល់ក្នុងបន្ទប់គេង គឺយើងអត់ពាក់ស្បែកជើង ឬក៏ទ្រនាប់ជើងទេ ព្រោះពេលខ្លះ ស្បែកជើង ឬក៏ទ្រនាប់ជើងដែលយើងពាក់យកមកពីក្រៅ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺមានធូលី ឬក៏មានដីប្រឡាក់ អញ្ចឹងប្រសិនបើយើងពាក់ចូលក្នុងផ្ទះ
គឺវាអាចធ្វើឲ្យប្រឡាក់ផ្ទះយើងបាន ដែលយើងឃើញក្មេងប្រុសម្នាក់នេះ
គឺគាត់អត់ពាក់ស្បែកជើងចូលក្នុងបន្ទប់របស់គាត់នោះទេ ដោយសារតែខ្លាចប្រឡាក់។
អញ្ចឹងគាត់បានដើរដោះស្បែកជើង ហើយសំដៅមករកបន្ទប់ទឹករបស់គាត់
ដោយយើងឃើញគាត់ចូលតាមទ្វារបន្ទប់ទឹក ដែលយើងឃើញបន្ទប់ទឹករបស់គាត់ នៅលើជញ្ជាំង
ក្បែរទ្វារ គឺមានបង្អួចកញ្ចក់មួយ អញ្ចឹងបង្អួចកញ្ចក់ គឺសម្រាប់ឲ្យខ្យល់ចេញចូលបាន
ព្រោះជាទូទៅបន្ទប់ទឹកគឺតូច ហើយហាប់ អត់សូវមានខ្យល់ចេញចូលទេ ដូច្នេះយើងត្រូវធ្វើបង្អួច
ដើម្បីកុំឲ្យហាប់។ អញ្ចឹងបង្អួចនេះ គឺយើងអាចបើកបិទបាន។ ដោយវានៅខ្ពស់ជាងយើងបន្តិច
ដូច្នេះគេអត់អាចមើលឃើញពីបង្អួចមកទេ អញ្ចឹងអ្នកដែលនៅខាងក្រៅបន្ទប់ទឹក
គឺគាត់អត់អាចមើលឃើញយើងតាមបង្អួចទេ ដោយសារតែបង្អួចនៅខ្ពស់ អញ្ចឹងនៅខ្ពស់ជាងយើង
អញ្ចឹងគេអត់អាចមើលឃើញទេ។ ហើយនៅក្បែរបង្អួចនោះ គឺមានទូកញ្ចក់មួយ
កូនទូកញ្ចក់ចាប់ជាប់ទៅនឹងជញ្ជាំង។ អញ្ចឹងយើងប្រើប្រាស់កូនទូកញ្ចក់នេះគឺ
ប្រើកញ្ចក់សម្រាប់ឆ្លុះមុខផង ហើយនៅក្នុងទូកញ្ចក់នោះ គឺយើងអាចដាក់សម្ភារៈផ្សេងៗផងដែរ
ដូចជាថ្នាំដុសធ្មេញ ច្រាសដុសធ្មេញ សាប៊ូដុសខ្លួន ឬក៏សាប៊ូកក់សក់ផងដែរ។
អញ្ចឹងជាទូទៅយើងប្រើប្រាស់ទូកញ្ចក់ កូនទូកញ្ចក់តូចមួយ ហើយដាក់ភ្ជាប់ទៅនឹងជញ្ជាំង
ដែលយើងឃើញនៅក្រោមទូកញ្ចក់ គឺមានឡាបូសម្រាប់លាងដៃមួយ។
អញ្ចឹងជាធម្មតានៅក្នុងបន្ទប់ទឹកនៅតាមទីក្រុង គឺយើងតែងតែដាក់នូវឡាបូសម្រាប់លាងដៃ
ដែលយើងឃើញឡាបូ នៅលើឡាបូគឺមានក្បាលរ៉ូប៊ីនេទឹកមួយ អញ្ចឹងក្បាលរ៉ូប៊ីនេទឹក
គឺមានកន្លែងសម្រាប់បើកទឹកម៉ាស៊ីនឲ្យហូរចេញមក។ អញ្ចឹងយើងអត់ចាំបាច់ទៅដួសទឹក
ដោយប្រើផ្តិល ឬក៏ដោយប្រើកាទឹកនោះទេ គឺយើងគ្រាន់តែមួលក្បាលរ៉ូប៊ីនេ
គឺទឹកនឹងចេញតាមបំពង់ទុយោហូរមកឲ្យយើងប្រើប្រាស់តែម្តង។
ដែលជាក់ស្តែងយើងឃើញនៅក្នុងរូបភាពនេះ គឺមានក្បាលរ៉ូប៊ីនេទឹកមួយនៅលើឡាបូលាងដៃ
សម្រាប់ឲ្យគាត់បើកទឹកលាងដៃ ឬក៏ដុសធ្មេញ ឬក៏លុបមុខទៅតាមតម្រូវការរបស់គាត់
ដែលជាទូទៅបើតាមនៅស្រុកស្រែចំការ គឺគាត់អត់មានទឹកម៉ាស៊ីនប្រើប្រាស់
អញ្ចឹងគាត់ប្រើប្រាស់ទឹករ៉ែក ឬអាចគាត់ដួស ដួសពីស្រះ ឬក៏ដួសពីបឹង
ហើយពេលខ្លះគាត់ប្រើប្រាស់ទឹកភ្លៀង អញ្ចឹងគាត់ត្រងទឹកភ្លៀង ប៉ុន្តែនៅក្នុងទីក្រុង
គឺយើងប្រើប្រាស់ទឹកម៉ាស៊ីន ដោយយើងប្រើប្រាស់ យើងបើកតែក្បាលរ៉ូប៊ីនេទឹក
នោះនឹងមានទឹកមកហូរមកឲ្យយើងប្រើប្រាស់។

បន្ទាប់មកទៀតរូបភាពទី ៤ រូបភាពទី ៤ យើងឃើញក្មេងប្រុសម្នាក់នោះ
គាត់បានច្របាច់ថ្នាំដុសធ្មេញដាក់លើច្រាសដុសធ្មេញរបស់គាត់ អញ្ចឹងជាទូទៅ មុនពេលចូលគេង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

យើងត្រូវដុសធ្មេញ ឬក៏ដុសសម្អាតធ្មេញយើងជាមុនសិន ដោយ យើង មួយថ្ងៃ
យើងត្រូវដុសធ្មេញបីដង គឺដើម្បីថែរក្សាធ្មេញយើងឲ្យបានស្អាត
ហើយធ្មេញរបស់យើងត្រូវដុសដោយប្រើថ្នាំដុសធ្មេញជាមួយនឹងច្រាសដុសធ្មេញ។
ដែលច្រាសដុសធ្មេញគឺជាច្រាសមួយដែលមានឈ្មោះទៅនឹងដាក់ចូលមាត់របស់យើងដើម្បីដុសធ្មេញ
ហើយសរសៃច្រាសគឺទន់ៗ គឺអត់រឹងដូចច្រាសបោកខោអាវនោះទេ។
ដែលយើងឃើញនៅក្នុងរូបភាពនេះគឺដៃម្ខាងរបស់ក្មេងប្រុសនោះកំពុងតែកាន់បំពង់ថ្នាំដុសធ្មេញ
ហើយដៃម្ខាងទៀតកំពុងតែកាន់ដងច្រាសដុសធ្មេញ
ដែលច្រាសដុសធ្មេញរបស់គាត់មានពណ៌ផ្កាឈូក ហើយសរសៃច្រាសដុសធ្មេញគឺមានពណ៌ស។
អញ្ចឹងគាត់កំពុងតែច្របាច់ថ្នាំដុសធ្មេញចេញពីបំពង់ថ្នាំដុសធ្មេញ
ហើយដាក់ថ្នាំដុសធ្មេញនោះមកលើច្រាសដុសធ្មេញ ដើម្បីយកទៅដុសធ្មេញ។ អញ្ចឹងយើងឃើញ
ជាធម្មតាថ្នាំដុសធ្មេញគឺដាក់ក្នុងបំពង់មួយដែលអាចច្របាច់បាន
ព្រោះនៅពេលដែលយើងត្រូវការដុសធ្មេញ គឺយើងគ្រាន់តែយកដៃច្របាច់បំពង់ថ្នាំដុសធ្មេញនោះ
នោះថ្នាំដុសធ្មេញនឹងចេញមកតាមមាត់បំពង់ ហើយយើងយកច្រាសដុសធ្មេញទៅត្រង
ដើម្បីដាក់ថ្នាំដុសធ្មេញយកមកដុសធ្មេញ។ ដែលជាក់ស្តែងយើងឃើញនៅក្នុងរូបភាពនេះ
គឺក្មេងប្រុសម្នាក់នោះ គាត់កំពុងតែច្របាច់ថ្នាំដុសធ្មេញចេញពីបំពង់ថ្នាំដុសធ្មេញ
ដើម្បីដាក់មកលើច្រាសដុសធ្មេញ ដើម្បីដុសធ្មេញ។

បន្ទាប់មកទៀតរូបភាពទី ៥ នៅក្នុងរូបភាពទី ៥ យើងឃើញថា
បន្ទាប់ពីគាត់ដាក់ថ្នាំដុសធ្មេញទៅលើច្រាសដុសធ្មេញរបស់គាត់ហើយ ក្មេងប្រុសម្នាក់នោះ
គាត់ក៏បានយកច្រាសដុសធ្មេញនោះមកដាក់ចូលក្នុងមាត់ ដើម្បីដុសសម្អាតធ្មេញរបស់គាត់។
អញ្ចឹងជាទូទៅ គឺយើងធ្វើការដុសសម្អាតធ្មេញមួយថ្ងៃបីដង ឬក៏ក្រោយពេលដែលយើងញ៉ាំអាហាររួច
ដែលយើងជាទូទៅយើងដុសធ្មេញនៅពេលព្រឹក ក្រោយពីយើងក្រោកពីគេង។
អញ្ចឹងបន្ទាប់ពីយើងក្រោកពីគេង យើងត្រូវដុសធ្មេញម្តង នៅពេលដែលយើងញ៉ាំអាហារថ្ងៃត្រង់រួច
យើងត្រូវដុសធ្មេញម្តង និងនៅពេលដែលយើងមុនចូលគេង មុនពេលដែលយើងចូលគេង
យើងត្រូវដុសធ្មេញម្តងទៀត ដើម្បីឲ្យប្រាកដថាធ្មេញរបស់យើងស្អាត
និងមិនមានកាកសំណល់ជាប់នឹងធ្មេញនោះទេ ព្រោះប្រសិនបើមានកាកសំណល់ជាប់នៅធ្មេញ
វាធ្វើអ្រាចឲ្យអាចធ្វើឲ្យធ្មេញពុក ឬក៏មានដង្កូវស៊ីធ្មេញ អញ្ចឹងអាចធ្វើឲ្យធ្មេញយើងខូច
ឬក៏យើងឈឺធ្មេញបាន។ ដូច្នេះយើងត្រូវដុសសម្អាតធ្មេញរបស់យើងឲ្យបានស្អាត
ហើយយើងត្រូវដុសសម្អាតអណ្តាតផងដែរ ព្រោះពេលខ្លះគឺបាក់តេរី ឬក៏មេរោគ
វានៅតោងជាប់នឹងអណ្តាត ដូច្នេះយើងត្រូវដុសសម្អាតអណ្តាត ជាមួយនឹងធ្មេញយើងឲ្យបានស្អាត
មុននឹងយើងចូលគេង។ ដែលជាក់ស្តែងយើងឃើញក្មេងប្រុសម្នាក់នេះ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គាត់កំពុងតែយកច្រាសដុសធ្មេញ ដែលមានថ្នាំដុសធ្មេញ ដុសទៅលើធ្មេញរបស់គាត់ ដោយគាត់យកច្រាសដុសធ្មេញនោះ ដាក់ចូលក្នុងមាត់ ហើយដុសចុះឡើងៗ ពីលើចុះក្រោម ពីក្រោមឡើងលើ ហើយពីឆ្វេងទៅស្ដាំ និងពីស្ដាំទៅឆ្វេងផងដែរ ដោយគាត់ដុសធ្មេញរបស់គាត់យ៉ាងយកចិត្តទុកដាក់ ដើម្បីឲ្យប្រាកដថា ធ្មេញរបស់គាត់គឺស្អាត មិនមានជាប់កាកសំណល់នោះទេ។
អញ្ចឹងយើងឃើញមានពពុះថ្នាំដុសធ្មេញជាច្រើនចេញពីមាត់របស់គាត់ ដោយយើងឃើញពពុះ ពពុះនោះគឺពពុះថ្នាំដុសធ្មេញ ព្រោះនៅពេលដែលយើងដាក់ថ្នាំដុសធ្មេញនៅលើច្រាស ហើយយើងយកមកដុសធ្មេញ គឺវានឹងមានពពុះចេញមក ហើយយើងអត់ត្រូវញ៉ាំពពុះនោះទេ ដោយសារតែពពុះនោះ គឺអាចធ្វើឲ្យយើងឈឺបាន អញ្ចឹងនៅពេលដែលយើងដុសហើយ គឺយើងត្រូវខ្ជាក់ពពុះនោះចោល ហើយប្រើប្រាស់ទឹកដើម្បីខ្ពុរមាត់ អញ្ចឹងយើងយកទឹកមកខ្ពុរមាត់ ដើម្បីខ្ពុរពពុះនោះចេញឲ្យអស់ ហើយឲ្យអស់ជាមួយនឹងកាកសំណល់ អញ្ចឹងយើងខ្ជាក់កាកសំណល់ជាមួយនឹងពពុះនោះចោល ព្រោះពពុះនោះគឺអត់ស្អាតនោះទេ នៅពេលដែលយើងដុសធ្មេញហើយ។ អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់កំពុងតែព្យាយាមដុសសម្អាតធ្មេញរបស់គាត់ឲ្យបានស្អាតមុននឹងចូលគេង ព្រោះគាត់ខ្លាចដង្កូវស៊ីធ្មេញ ឬក៏គាត់ខ្លាចមានក្លិនមាត់មិនល្អ នៅពេលដែលយើងភ្លេចដុសធ្មេញ វាអាចធ្វើឲ្យយើងមានក្លិនមិនល្អនៅក្នុងមាត់ ហើយម្យ៉ាងវិញទៀតធ្វើឲ្យធ្មេញយើងពុកនិងឆាប់បាក់ ដូច្នេះគាត់ត្រូវដុសធ្មេញគាត់ឲ្យបានស្អាត។

បន្ទាប់មកទៀតរូបភាពគឺទី ៦ នៅក្នុងរូបភាពទី ៦ បន្ទាប់ពីគាត់ដុសធ្មេញគាត់ស្អាតហើយ អញ្ចឹងគាត់បានដុសសម្អាតធ្មេញរបស់គាត់បានយ៉ាងស្អាត បន្ទាប់មកគាត់ក៏បានចេញពីបន្ទប់ទឹក អញ្ចឹងគាត់ដើរសំដៅចូលមកក្នុងបន្ទប់គេងរបស់គាត់ ដោយដើរសំដៅមករកគ្រែគេង។ ដែលនៅក្នុងរូបភាពទី ៦ នេះ យើងឃើញគាត់កំពុងតែដើរចូលតាមមាត់ទ្វារ អញ្ចឹងគាត់ឈានជើងចូលក្នុងបន្ទប់គេងរបស់គាត់តាមមាត់ទ្វារ ហើយដើរសំដៅមករកគ្រែគេងរបស់គាត់។ ដោយយើងឃើញនៅក្បែរគាត់គឺមានគ្រែគេងមួយ។ អញ្ចឹងគ្រែគេងនោះ យើងឃើញនៅលើគ្រែគេងគឺមានពូកមួយ និងមានភួយមួយ ហើយមានខ្នើយកើយចំនួនមួយផងដែរនៅលើគ្រែ ដែលពួកយើងប្រើសម្រាប់គេងទីលើនោះ អញ្ចឹងនៅពេលដែលយើងគេង គឺយើងគេងនៅលើពូក សម្រាប់អ្នកទីក្រុងគឺយើងគេងនៅលើពូក ចំណែកឯអ្នកអត់មានពូកគេងគឺគេងនៅលើកន្ទេល។ អញ្ចឹងគាត់គេងនៅលើពូក ហើយដណ្ដប់ភួយ។ ភួយដែលដាក់នៅលើគ្រែ គឺគាត់ដណ្ដប់ភួយ ដោយយកភួយដណ្ដប់លើខ្លួនរបស់គាត់។ ហើយគាត់នឹងកើយនៅលើខ្នើយ នៅពេលដែលគាត់គេង។ អញ្ចឹងគ្រែនេះគឺយើងឃើញមានជើងបួន គ្រែជើងបួន

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

ប៉ុន្តែនៅក្នុងរូបភាពទី ៦ គឺមានជើងតែបីទេ ដោយសារតែបាំងមួយ
អញ្ចឹងប្រសិនបើយើងមើលជុំវិញគ្រែ គឺយើងឃើញ នឹងឃើញមានជើងបួនជាក់ជាមិនខាន
ដោយសារតែគ្រែតែងតែមានជើងបួន។ ហើយនៅក្បែរគ្រែនៅជាប់ជញ្ជាំង
យើងឃើញមានបង្អួចមួយ ដែលបង្អួចនោះគឺជាបង្អួចកញ្ចក់ អញ្ចឹងបង្អួចកញ្ចក់
គឺជាបង្អួចដែលអាចឲ្យយើងមើលឃើញទៅខាងក្រៅបាន អញ្ចឹងយើងអត់ចាំបាច់បើកបង្អួចទេ
ក៏យើងអាចមើលឃើញទៅខាងក្រៅដែរ ដោយសារតែវាជាកញ្ចក់
អញ្ចឹងយើងអាចមើលឃើញឆ្លងកញ្ចក់បាន បានន័យថាយើងអាចមើលឃើញពីម្ខាងទៅម្ខាងបាន
ដោយមិនចាំបាច់បើកកញ្ចក់នោះទេ។ ក៏ប៉ុន្តែបង្អួចរបស់គាត់យើងឃើញមានវាំងននពីរ។
អញ្ចឹងវាំងននបង្អួចគឺប្រើប្រាស់សម្រាប់បិទឬក៏បើកនៅពេលដែលយើងមិនចង់ឲ្យមានពន្លឺចូល។
អញ្ចឹងពេលខ្លះប្រសិនបើយើងខ្លាចចាំងថ្ងៃឬក៏កុំចង់ឲ្យមានពន្លឺព្រះចន្ទចូលនៅពេលដែលយើងគេង
យើងអាចទាញវាំងននបិទបង្អួចបាន ប៉ុន្តែប្រសិនបើយើងគិតថាចង់មើលព្រះចន្ទ
ឬក៏ចង់ឲ្យមានពន្លឺចេញចូលក្នុងបន្ទប់របស់យើង
យើងគ្រាន់តែទាញវាំងននចេញពីបង្អួចនោះជាការស្រេច គឺអាចធ្វើឲ្យមានពន្លឺចេញចូលបាន។
អញ្ចឹងវាំងននគឺដាក់សម្រាប់ដើម្បីបាំងកុំឲ្យមានពន្លឺចូល ចូលទៅក្នុងបង្អួច
ឬក៏កុំឲ្យមាននរណាម្នាក់មើលឃើញយើងពីក្រៅតាមរយៈបង្អួចនោះបាន។

បន្ទាប់មកទៀតរូបភាពទី ៧ នៅក្នុងរូបភាពទី ៧ យើងឃើញក្មេងប្រុសម្នាក់នោះ
គាត់បានដើរទៅបើកកង្ហាររបស់គាត់ឲ្យវិល។ អញ្ចឹងជាធម្មតា ដើម្បីឲ្យត្រជាក់នៅក្នុងបន្ទប់
ប្រហែលជាបន្ទប់របស់គាត់គឺជាបន្ទប់បិទជិត ដូច្នេះវាអាចនឹងក្តៅ វាអាចធ្វើឲ្យយើង ឲ្យគាត់ក្តៅ
ក្តៅស្អុះ អញ្ចឹងដើម្បីឲ្យមានភាពត្រជាក់ គឺគាត់ត្រូវប្រើកង្ហារ អញ្ចឹងអ្នកខ្លះនៅពេលដែលគាត់ជា មាន
មានលុយ គាត់អាចទិញជាម៉ាស៊ីនត្រជាក់ ដើម្បីដាក់នៅក្នុងបន្ទប់របស់គាត់
អញ្ចឹងគាត់អត់ចាំបាច់ប្រើកង្ហារទេ គាត់អាចប្រើជាម៉ាស៊ីនត្រជាក់
ហើយគាត់គ្រាន់តែបើកម៉ាស៊ីនត្រជាក់ គឺបន្ទប់របស់គាត់នឹងត្រជាក់។
ក៏ប៉ុន្តែប្រហែលជាក្មេងប្រុសម្នាក់នេះគាត់អត់មានម៉ាស៊ីនត្រជាក់ទេ
នៅក្នុងបន្ទប់របស់គាត់អត់មានម៉ាស៊ីនត្រជាក់ទេ ដូច្នេះគាត់ប្រើប្រាស់កង្ហារ ដែលយើង[កង្ហារ]
ឃើញកង្ហាររបស់គាត់គឺមានពណ៌ផ្កាឈូក ហើយស្លាបកង្ហារគឺមានចំនួនបីមុំ
អញ្ចឹងយើងមានស្លាបកង្ហារចំនួនបីមុំ ដើម្បីបក់ឲ្យមានខ្យល់ចេញពីកង្ហារនោះ ដើម្បីឲ្យយើងត្រជាក់។
ហើយកង្ហាររបស់គាត់គឺជាកូនកង្ហារតូច ដែលដាក់នៅលើកៅអីមួយ
អញ្ចឹងគាត់មានកូនកៅអីតូចមួយដើម្បីដាក់កង្ហារ ដែលកៅអី កូនកៅអីនោះ ក៏មានជើងបួនផងដែរ
ដើម្បីទ្រ ហើយយើងឃើញមានកង្ហារ គឺមានប៊ូតុងសម្រាប់ចុច។ អញ្ចឹងប៊ូតុងសម្រាប់ចុច
គឺជាប៊ូតុងសម្រាប់កំណត់ល្បឿនកង្ហារឲ្យវិលខ្លាំងឬក៏ឲ្យវិលខ្សោយ តាមតម្រូវការរបស់យើង។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងប្រសិនបើយើងចង់បានខ្យល់ខ្លាំង គឺយើងចុចប៊ូតុងដែលធ្វើឲ្យកង្ហាររិលខ្លាំង អញ្ចឹងស្លាបកង្ហារនឹងវិលខ្លាំង ហើយខ្យល់នឹងបញ្ចេញមកខ្លាំង។ ក៏ប៉ុន្តែប្រសិនបើយើងអត់ចូលចិត្តខ្យល់ខ្លាំងទេ យើងអាចបន្ថយល្បឿនកង្ហារ ដោយចុចប៊ូតុងផ្សេងទៀត ដើម្បីឲ្យវាដំណើរការវិលយឺតៗ ធ្វើឲ្យខ្យល់ចេញតិចៗ។ អញ្ចឹងក្មេងប្រុសម្នាក់នេះ គាត់ បន្ទាប់ពីគាត់ចូលទៅក្នុងបន្ទប់ហើយ គាត់ក៏បានមកដើរ បើកកង្ហារឲ្យវិល ដើម្បីឲ្យមានខ្យល់ត្រជាក់នៅក្នុងបន្ទប់របស់គាត់។

បន្ទាប់មកទៀតរូបភាពទី ៨ នៅក្នុងរូបភាពទី ៨ យើងឃើញថា បន្ទាប់ពីគាត់បើកកង្ហារហើយ ក្មេងប្រុសម្នាក់នោះ គាត់ក៏ចាប់ផ្តើមផ្លាស់សម្លៀកបំពាក់របស់គាត់ចេញ ព្រោះពេលខ្លះ នៅពេលដែលយើងមកពីក្រៅ សម្លៀកបំពាក់ដែលយើងពាក់មកពីក្រៅ គឺធ្វើឲ្យមានការប្រឡាក់ បានន័យថានៅពេលដែលយើងដើរលេងនៅខាងក្រៅ ឬក៏ធ្វើការអាចមានដីហុយនៅតាមផ្លូវ ឬក៏អាចមានប្រឡាក់នូវធូលីតាមផ្លូវបាន ដូច្នេះយើងអត់ត្រូវពាក់ខោអាវ ដែលយើងពាក់មកពីក្រៅគេងនោះទេ។ ព្រោះវាអាចធ្វើឲ្យយើងមិនស្រួលខ្លួន ឬក៏ស្អុះស្អាប់ ឬក៏ស្អៀប ដោយសារតែមានប្រឡាក់នៅ នៅជាប់នឹងខោអាវ។ ម្យ៉ាងវិញទៀត ខោអាវដែលយើងពាក់នៅតាមផ្លូវ នៅចេញទៅក្រៅ វាអាចជាខោអាវដែលមានដៃវែង ជើងវែង ឬក៏ក្រាស់ៗ អញ្ចឹងយើងពាក់ទៅអត់ស្រួលខ្លួនទេនៅពេលដែលយើងគេង។ ព្រោះខោអាវក្រាស់ៗគឺយើងពាក់ទៅក្រៅដើម្បីការពារកម្តៅថ្ងៃ អញ្ចឹងនៅពេលដែលយើងចូលដល់បន្ទប់គេង ប្រសិនបើយើងពាក់ខោអាវក្រាស់ៗ គឺវាអាចធ្វើឲ្យយើងគេងមិនស្រួល បានន័យថាគេងលក់អត់ស្រួល អញ្ចឹងយើងត្រូវផ្លាស់ខោអាវ ដែលយើងពាក់ចេញទៅក្រៅចេញ ដោយយើងផ្លាស់ជំនួសមកវិញនូវខោអាវដែលគេងយប់។ អញ្ចឹងជាក់ស្តែងនៅក្នុងរូបភាពទី ៨ នេះ ក្មេងប្រុសម្នាក់នោះ គាត់ក៏បានស្រាតខោគាត់ចេញ អញ្ចឹងគាត់ស្រាតខោខ្មៅជើងវែងរបស់គាត់ចេញ ដោយយើងឃើញខោខ្មៅជើងវែងរបស់គាត់ គាត់ស្រាតហើយ គាត់ដាក់នៅលើគ្រែគេងរបស់គាត់។ អញ្ចឹងគាត់ស្រាតខោចេញ គាត់ស្លៀកតែខោលីអូតែប៉ុណ្ណោះ។ អញ្ចឹងជាទូទៅ យើងស្លៀកខោជើងវែងផង យើងស្លៀកខោលីអូផង ឬក៏ខោទ្រនាប់ ឬក៏ខោក្នុង យើងអាចហៅបានបី យើងអាចហៅថាខោលីអូ យើងហៅថាខោក្នុង ឬក៏ហៅថាខោទ្រនាប់បាន។ អញ្ចឹងយើងឃើញគាត់ស្លៀកខោលីអូពណ៌ស ហើយគាត់កំពុងតែដោះអាវរបស់គាត់ចេញផងដែរ បានន័យថាគាត់កំពុងតែផ្លាស់ខោអាវ។ អញ្ចឹងគាត់លើកដៃឡើង ហើយចាប់ទាញកអាវរបស់គាត់ឡើងឲ្យផុតពីមុខ អញ្ចឹងគាត់ដោះអាវក្រៅ ដោះអាវរបស់គាត់ចេញ ដែលគាត់ពាក់ទៅខាងក្រៅ អញ្ចឹងគាត់ដោះអាវរបស់គាត់ចេញ ដោយផ្លាស់សម្លៀកបំពាក់គេងយប់។ អញ្ចឹងគាត់នឹងផ្លាស់សម្លៀកបំពាក់គេងយប់ ដោយ ដោយប្តូរពីខោអាវពាក់ទៅខាងក្រៅ មកជាសម្លៀកបំពាក់គេងយប់វិញ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

បន្ទាប់មកទៀតរូបភាពទី ៩ នៅក្នុងរូបភាពទី ៩ យើងឃើញថា បន្ទាប់ពីគាត់ដោះខោអាវ ដែលគាត់ពាក់ចេញទៅក្រៅរួចរាល់ហើយ គាត់ក៏បានពាក់ខោអាវគេងយប់ចូល ឬក៏គាត់ពាក់ខោអាវផ្សេងទៀត ដែលមានលក្ខណៈរលុង ហើយនិងទន់ ស្រួល ងាយស្រួល ធ្វើ ក្នុងការ ធ្វើឲ្យគាត់គេងលក់ស្រួល។ ដែលនៅក្នុងរូបភាពទី ៩ យើងឃើញខោជើងវែងពណ៌ខ្មៅ ជាមួយនឹងអាវដៃខ្លីពណ៌ខៀវដែលគាត់ពាក់ទៅខាងក្រៅអម្បាញ់មិញ គឺគាត់បានទុកនៅលើគ្រែ គាត់អត់ទាន់បត់យកទៅណាទេ អញ្ចឹងគាត់កំពុងតែទុកខោអាវទាំងពីរនៅលើគ្រែ ហើយគាត់កំពុងតែពាក់ខោជើងខ្លីពណ៌សវិញ អញ្ចឹងគាត់ស្លៀកខោជើងខ្លីពណ៌ស ជំនួសឲ្យខោជើងវែងពណ៌ខ្មៅ ដើម្បីគេង បន្ទាប់មកគាត់ក៏បានពាក់អាវដៃខ្លីពណ៌លឿង អញ្ចឹងគាត់ពាក់អាវយឺតដៃខ្លីពណ៌លឿង ដើម្បីគេង ព្រោះប្រហែលជាអាវយឺតដៃខ្លីពណ៌លឿងនោះ គឺធំជាងខ្លួនគាត់ និងមានលក្ខណៈរលុង និងត្រជាក់ ដូច្នេះធ្វើឲ្យគាត់ អាចធ្វើឲ្យគាត់គេងលក់ស្រួលបាន អញ្ចឹងគាត់ផ្លាស់ខោអាវ ពាក់ខោអាវទៅខាងក្រៅចេញ ហើយគាត់ពាក់ ឬក៏ស្លៀកពាក់ខោអាវគេងយប់ចូលដើម្បីគេងនៅក្នុងយប់នេះ ព្រោះវាអាចធ្វើឲ្យគាត់គេងលក់ស្រួលបាន និងវាមិនធ្វើឲ្យគាត់ស្អៀប ឬក៏រមាស់ ឬក៏មិនធ្វើឲ្យគាត់មានមេរោគទៅជាប់ខ្លួននោះទេ ដោយគាត់តែផ្លាស់ខោអាវដែលប្រឡាក់ចេញ និងពាក់ខោអាវថ្មីចូល។

បន្ទាប់មកទៀតរូបភាពទី ១០ រូបភាពទី ១០ យើងឃើញថា បន្ទាប់ពីគាត់ស្លៀកពាក់ខោអាវហើយ អញ្ចឹងគាត់ផ្លាស់ខោអាវរួចរាល់ហើយ ក្មេងប្រុសម្នាក់នោះ គាត់ក៏បានឡើងមកអង្គុយនៅលើគ្រែ អញ្ចឹងគាត់អត់ទាន់គេងភ្លាមទេ គឺគាត់មកអង្គុយដោយផ្អែកខ្នងគាត់ទៅនឹងក្បាលគ្រែ ហើយគាត់ដាក់ខ្នើយដើម្បីផ្អែកទៅនឹងខ្នងរបស់គាត់ បន្ទាប់មកគាត់អង្គុយសណ្ដូកជើង ដោយជើងម្ខាងរបស់គាត់សណ្ដូកនៅលើគ្រែ ជើងម្ខាងទៀត គឺគាត់បញ្ឈរជង្គង់ឡើង។ អញ្ចឹងគាត់កំពុងតែអង្គុយសណ្ដូកជើងនិងបញ្ឈរជង្គង់នៅលើគ្រែ ដោយជើងស្ដាំ យើងឃើញគាត់សណ្ដូកនៅលើគ្រែ ដោយជើងឆ្វេង គាត់ឃើញ យើងឃើញគាត់បញ្ឈរជង្គង់ឡើង ហើយគាត់អង្គុយនៅលើភួយ ដោយដាក់ដៃនៅលើជើងរបស់គាត់ អញ្ចឹងគាត់ដាក់ដៃស្ដាំនៅលើជើងស្ដាំរបស់គាត់ ហើយដៃឆ្វេងគឺគាត់ទម្លាក់នៅលើគ្រែ។ អញ្ចឹងយើងឃើញក្បែរគ្រែរបស់គាត់ គឺមានកូនកៅអីតូចមួយសម្រាប់ដាក់កង្ហារ ដែលកង្ហារកំពុងតែវិលបញ្ចេញខ្យល់ចេញមកក្រៅ អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់អត់ប្រើម៉ាស៊ីនត្រជាក់ទេ គឺគាត់ប្រើកង្ហារ អញ្ចឹងគាត់បើកកង្ហារឲ្យមានខ្យល់ ដើម្បីឲ្យខ្លួនគាត់ត្រជាក់ ដែលយើងឃើញនៅក្បែរកៅអីកង្ហារនោះ គឺយើងឃើញមានកូនតុមួយ ឬក៏កូនទូមួយ ដែលកូនទូនោះយើងឃើញមានចំនួនបីថត

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងកូនទូនេះគឺប្រើសម្រាប់ដាក់ទ្រទូរទស្សន៍ ដោយយើងឃើញនៅលើកូនទូនោះ
គឺមានទូរទស្សន៍មួយ ដែលទូរទស្សន៍នោះកំពុងតែបិទ។
អញ្ចឹងគាត់មានទូរទស្សន៍មួយដាក់នៅលើកូនទូ ដែលកូនទូនោះគឺមានចំនួនបីថតដែលយើង
ថតទាំងបីនោះ គឺយើងអាចដាក់សម្ភារៈផ្សេងៗ ដូចជាតេឡេទូរទស្សន៍ ឬក៏សៀវភៅ
ឬក៏ខោអាវនានាបាន អញ្ចឹងថតទូគឺប្រើប្រាស់សម្រាប់ដាក់សម្ភារៈផ្សេងៗចូលទៅក្នុងទូ
ហើយទូរទស្សន៍ គឺជាគ្រឿងអេឡិចត្រូនិច ឬក៏ជាឧបករណ៍អេឡិចត្រូនិច
ដែលអាចធ្វើឲ្យយើងមើលជារឿង ឬក៏មើលជាវីដេអូ ឬក៏មើលព័ត៌មានបាន។ អញ្ចឹងយើងមើលវីដេអូ
មើលរឿង មើលព័ត៌មាន ដោយប្រើប្រាស់ទូរទស្សន៍។ ដែលយើងឃើញទូរទស្សន៍របស់គាត់
គឺនៅលើកូនទូតូចមួយ ដែលមានចំនួនបីថត។ ហើយនៅលើជញ្ជាំងរបស់គាត់គឺមានបង្អួច
ដែលបង្អួចគាត់គេងអត់បិទវាំងននទោះទេ។ អញ្ចឹងបានន័យថាគាត់ចូលចិត្តភ្លឺ
គាត់ចង់បានពន្លឺព្រះចន្ទ ដូច្នេះគាត់អត់បិទវាំងននបង្អួចរបស់គាត់នោះទេ
ដោយគាត់បើកចំហវាំងននរបស់គាត់។ អញ្ចឹងក្មេងប្រុសម្នាក់នោះ
បន្ទាប់ពីគាត់ផ្លាស់សម្លៀកបំពាក់រួចហើយ គាត់អត់ទាន់ចូលគេងភ្លាមទេ
គឺគាត់អង្គុយសណ្តូកជើងនៅលើគ្រែរបស់គាត់ ដោយអង្គុយបញ្ឈរជង្គង់ម្ខាង
និងសណ្តូកជើងម្ខាងនៅលើគ្រែ នៅខាងមុខទូរទស្សន៍។

បន្ទាប់មកទៀតរូបភាពទី ១១ រូបភាពទី ១១ យើងឃើញ បន្ទាប់ពីគាត់អង្គុយបានបន្តិចក្រោយមក
គាត់នឹកចង់មើលទូរទស្សន៍ ដូច្នេះគាត់ក៏យកតេឡេមកបញ្ជា អញ្ចឹងយើងហៅថាតេឡេ
ឬក៏ឧបករណ៍បញ្ជា យើងឃើញគាត់ចុចប៊ូតុងតេឡេ ដើម្បីបើកទូរទស្សន៍
អញ្ចឹងគាត់កំពុងតែមើលព័ត៌មាន ដោយយើងឃើញគាត់កំពុងតែចុចតេឡេដើម្បីបើកទូរទស្សន៍
ពេលនោះទូរទស្សន៍ក៏បានបើក ហើយទូរទស្សន៍កំពុងតែផ្សាយព័ត៌មានអំពីទឹកលិច
ឬក៏ទឹកជំនន់នៅក្នុងថ្ងៃនេះ ដែលប្រហែលជាថ្ងៃនេះមានភ្លៀងធ្លាក់ខ្លាំង
ដូច្នេះយើងឃើញនៅក្នុងទូរទស្សន៍ គឺគេផ្សាយព័ត៌មានអំពីទឹកលិច។
ដែលយើងឃើញនៅក្នុងទូរទស្សន៍នេះ យើងឃើញមានបុរសម្នាក់ គាត់ស្លៀកខោជើងខ្លី
ពាក់អាវដៃខ្លីកាន់ឆត្រ ហើយគាត់កំពុងតែដើរនៅក្នុងទឹក ឬក៏ដើរលុយទឹក
បានន័យថាគាត់កំពុងតែដើរនៅក្នុងទឹកជំនន់ ដែលប្រហែលជាមានភ្លៀងខ្លាំងនៅក្នុងថ្ងៃនេះ
ដូច្នេះធ្វើឲ្យទីក្រុងគឺមានទឹកលិច។ ដោយយើងឃើញនៅក្បែរបុរសម្នាក់នោះគឺមានឆ្កែមួយ
កំពុងតែហែលទឹកផងដែរ អញ្ចឹងឆ្កែកំពុងតែហែលទឹកដោយសារតែមានទឹកជំនន់ មានទឹកលិចខ្លាំង
ដូច្នេះហើយធ្វើឲ្យពិបាកនៅក្នុងការរស់នៅ ដែលមនុស្សនិងសត្វ ពិបាកក្នុងការរស់នៅ
ដោយត្រូវឆ្លងទឹក ឬក៏ហែលទឹក ឬក៏ដើរកាត់ទឹក។ អញ្ចឹងនៅក្នុងនោះ នៅក្នុងទូរទស្សន៍នោះ
យើងឃើញមានស្ត្រីម្នាក់ផងដែរ ដែលគាត់កំពុងតែយួរកាបូប ឬក៏យួរថង់អីវ៉ាន់របស់គាត់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

លើកឲ្យផុតពីទឹក អញ្ចឹងគាត់កំពុងតែដើរ ហើយគាត់មិនចង់ឲ្យអីវ៉ាន់របស់គាត់សើម ឬក៏ទទឹក ដូច្នេះគាត់ព្យាយាមលើកឲ្យផុតទឹក។ អញ្ចឹងប្រហែលជាថ្ងៃនេះគឺជាថ្ងៃដែលមានភ្លៀងធ្លាក់ខ្លាំង ឬក៏ថ្ងៃដែលមានទឹកជំនន់ ដូច្នេះហើយទើបមានព័ត៌មានអំពីទឹកជំនន់កើតឡើងនៅក្នុងថ្ងៃនេះ ដែលផ្សាយនៅក្នុងទូរទស្សន៍។ អញ្ចឹងក្មេងប្រុសម្នាក់នោះ គាត់ក៏បានបើកទូរទស្សន៍ មើលព័ត៌មានអំពីទឹកជំនន់នៅក្នុងថ្ងៃនេះ។

បន្ទាប់មកទៀតរូបភាពទី ១២ នៅក្នុងរូបភាពទី ១២ យើងឃើញថាបន្ទាប់ពីបើកទូរទស្សន៍រួច ក្មេងប្រុសម្នាក់នោះ គាត់ក៏បានអង្គុយសណ្ដូកជើងទាំងពីររបស់គាត់នៅលើគ្រែ ហើយអង្គុយមើលទូរទស្សន៍អំពីទឹកជំនន់ ដែលយើងឃើញទូរទស្សន៍ដែលនៅលើកូនទូ ដែលមានបីថតនោះ គឺកំពុងតែផ្សាយព័ត៌មានអំពីទឹកជំនន់ ដែលយើងឃើញមានបុរសម្នាក់ កំពុងតែជិះម៉ូតូកាត់ទឹក។ អញ្ចឹងនៅពេលដែលមានទឹកជំនន់ គឺធ្វើឲ្យយើងពិបាកធ្វើដំណើរ ដោយសារតែ[ទីកន្លែង] គ្រប់ទីកន្លែង គឺមានទឹកដក់ ឬក៏មានទឹកលិច។ អញ្ចឹងរាល់ការធ្វើដំណើរដោយថ្មើរជើង ឬក៏ការដើរ ឬក៏ការជិះម៉ូតូ ឬក៏ការជិះឡាន គឺនឹងមានការលំបាក ដោយសារតែយើងត្រូវជិះកាត់ទឹក ដូច្នេះវាអាចធ្វើឲ្យយើងមិនប្រុងប្រយ័ត្ន ប្រសិនបើយើងមិនប្រុងប្រយ័ត្ន វាអាចធ្វើឲ្យយើងមានគ្រោះថ្នាក់បាន នៅពេលដែលយើងធ្វើដំណើរនៅក្នុងទឹក។ អញ្ចឹងរូបភាពទី ១២ នេះ ក្មេងប្រុសម្នាក់នោះ គាត់កំពុងតែមើលព័ត៌មានអំពីទឹកជំនន់នៅក្នុងថ្ងៃនេះ។

បន្ទាប់មកទៀតរូបភាពទី ១៣ រូបភាពទី ១៣ ប្រហែលជាព័ត៌មានអំពីទឹកជំនន់នោះចប់ ឬក៏ដោយសារតែគាត់ងងុយគេងខ្លាំង ដូច្នេះគាត់ក៏បានយកតេឡេមកបិទទូរទស្សន៍ អញ្ចឹងគាត់ក៏បានយកតេឡេមកចុចលើប៊ូតុង ឬក៏ចុចលើគ្រាប់ចុចតេឡេ ដើម្បីបញ្ជាឲ្យបិទទូរទស្សន៍ ដូច្នេះគាត់អត់ចាំបាច់ដើរទៅបិទទូរទស្សន៍ផ្ទាល់នោះទេ គឺគាត់គ្រាន់តែអង្គុយនៅលើគ្រែ ហើយប្រើប្រាស់ប្រដាប់បញ្ជា ឬក៏តេឡេចុចទៅលើទូរទស្សន៍ នោះទូរទស្សន៍នឹងបិទ។ ដែលនៅក្នុងរូបភាពទី ១៣ នេះ យើងឃើញគាត់កំពុងតែប្រើប្រាស់មេដៃរបស់គាត់ ដើម្បីចុចប៊ូតុងរបស់ទូរទស្សន៍ គាត់កំពុងតែចុចប៊ូតុងរបស់តេឡេ បន្ទាប់មកយើងឃើញទូរទស្សន៍ក៏ចាប់ផ្ដើមបិទ។ អញ្ចឹងនៅពេលដែលទូរទស្សន៍បិទ យើងឃើញកញ្ចក់ទូរទស្សន៍គឺមានពណ៌ខ្មៅ អញ្ចឹងអត់មានរូបភាពអីផ្សាយទៀតទេ ដោយសារតែគាត់បិទទូរទស្សន៍នោះហើយ។

បន្ទាប់មកទៀតរូបភាពទី ១៤ រូបភាពទី ១៤ ដោយសារតែគាត់ងងុយគេងខ្លាំង អញ្ចឹងគាត់ក៏បានបិទភ្លើង ហើយក៏គាត់ក៏បានបិទទូរទស្សន៍ ហើយគាត់ក៏បានគេងនៅលើគ្រែ

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អញ្ចឹងគាត់ក៏បានគេងដោយដណ្តប់ភួយ ដោយគាត់កើយនៅលើខ្នើយ។
អញ្ចឹងក្បាលរបស់គាត់កើយនៅលើខ្នើយ ហើយគាត់យកភួយមកដណ្តប់
ដែលអម្បាញ់មិញគាត់អង្គុយសណ្តូកជើងនៅលើភួយ ប៉ុន្តែនៅពេលដែលគាត់គេង
គឺគាត់ចូលទៅក្រោមភួយ បានន័យថាគាត់ដណ្តប់ភួយ ប្រហែលជាអាកាសធាតុនៅថ្ងៃនេះ
គឺរៀងត្រជាក់បន្តិច។ អញ្ចឹងដោយសារតែមានមេឃភ្លៀង ហើយមានទឹកជំនន់
ដូច្នេះអាកាសធាតុប្រហែលជាត្រជាក់បន្តិច ដូច្នេះធ្វើឲ្យគាត់រងា មានអារម្មណ៍ថាត្រជាក់
អញ្ចឹងគាត់ត្រូវដណ្តប់ភួយដើម្បីឲ្យមានភាពកក់ក្តៅ អញ្ចឹងគាត់ ប្រសិនបើគាត់អត់បើកកង្ហារទេ
គឺអាចធ្វើឲ្យគាត់ហប់នៅក្នុងបន្ទប់ ដោយសារតែបន្ទប់របស់គាត់គឺហប់
អញ្ចឹងគាត់ត្រូវបើកកង្ហារឲ្យមានខ្យល់ចេញចូល ក៏ប៉ុន្តែដោយសារតែអាកាសធាតុត្រជាក់
អញ្ចឹងគាត់ត្រូវការដណ្តប់ភួយ គេងដណ្តប់ភួយ ដើម្បីឲ្យគាត់មានភាពកក់ក្តៅបាន។
អញ្ចឹងនៅក្នុងរូបភាពទី ១៤ យើងឃើញគាត់កំពុងតែប្រាស់ខ្លួនគេង
គឺគាត់កំពុងតែប្រាស់ខ្លួនគេងនៅលើពូក ហើយកើយនៅលើខ្នើយ
ដោយគាត់គេងដណ្តប់ភួយផងដែរ។ អញ្ចឹងគាត់គេងផ្អៀងមកស្តាំ បានន័យថាគាត់ផ្អៀងមកស្តាំ
ដើម្បីងាយស្រួលគេង។ អញ្ចឹងអ្នកខ្លះគាត់ទម្លាប់គេងផ្អៀងទៅឆ្វេង
អ្នកខ្លះគាត់ទម្លាប់គេងផ្អៀងមកស្តាំ រីឯអ្នកខ្លះទៀតគាត់ទម្លាប់គេងផ្ងារឡើងលើ។
អញ្ចឹងទៅតាមទម្លាប់នីមួយៗ អ្នកខ្លះគាត់គិតថាគេងផ្អៀងគឺងាយស្រួលគេង
អ្នកខ្លះគេងផ្ងារគឺងាយស្រួលគេង។ អញ្ចឹងគេ គាត់ បុរសម្នាក់នេះ គាត់គេងទៅតាមទម្លាប់របស់គាត់
ដើម្បីឲ្យងាយស្រួលគេងនិងឆាប់គេងលក់។

បន្ទាប់មកទៀតរូបភាពទី ១៥ នៅក្នុងរូបភាពទី ១៥ ក្រោយពីគាត់ប្រាស់ខ្លួនគេងបន្តិចមក
ប្រហែលជាគាត់ដោយសារតែគាត់អស់កម្លាំង អញ្ចឹងប្រហែលជាគាត់ដោយសារអស់កម្លាំងពេក
ដោយគាត់មកពីក្រៅ ឬក៏គាត់ធ្វើការអស់កម្លាំងពេក គាត់គេងបន្តិច ក្រោយមកគាត់ក៏គេងលក់
អញ្ចឹងគាត់ក៏បានគេងលក់ ដោយយើងឃើញខ្យល់កង្ហារកំពុងតែបក់។ អញ្ចឹងគាត់បើកកង្ហារ
ហើយគាត់គេងនៅលើគ្រែ អញ្ចឹងយើងឃើញខ្យល់កង្ហារកំពុងតែបក់មកលើគាត់
ហើយបុរសម្នាក់នោះគាត់ក៏បានគេងលក់ ដែលគាត់គេងឆាប់លក់ដោយសារតែគាត់អស់កម្លាំង។
អញ្ចឹងអ្នកខ្លះគាត់ពិបាកក្នុងការគេងលក់ ដោយសារតែគាត់ត្រូវគិតច្រើន
អញ្ចឹងគាត់អាចប្រើប្រាស់ពេលយូរ ដើម្បីសម្ងំគេង ដោយអ្នកខ្លះគាត់អាចសម្ងំគេងមួយម៉ោង
ឬក៏កន្លះម៉ោង មុននឹងគាត់អាចគេងលក់បាន ដោយសារតែគាត់នឹកគិតរឿងផ្សេងៗ
ដែលគាត់បានធ្វើពីថ្ងៃ ឬក៏គាត់គិតថាតើថ្ងៃស្អែកគាត់នឹងត្រូវធ្វើអ្វីទៀត។
ចំណែកឯក្មេងប្រុសម្នាក់នេះ ដោយសារតែគាត់អស់កម្លាំងខ្លាំងពេក
និងដោយសារតែគាត់ងងុយគេងផង ដូច្នេះនៅពេលដែលគាត់គេងបានបន្តិច គឺគាត់បានគេងលក់

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

គឺគាត់អត់ប្រើប្រាស់ពេលយូរ ដើម្បីសម្ងំគេងដូចគេដទៃទៀតនោះទេ។ អញ្ចឹងនៅក្នុងរូបភាពទី ១៥ គឺក្មេងប្រុសម្នាក់នោះគាត់ក៏បានគេងលក់។

បន្ទាប់មកទៀតរូបភាពទី ១៦ នៅក្នុងរូបភាពទី ១៦ នៅពេលដែលគាត់គេង អញ្ចឹងជាទូទៅ នៅពេលដែលយើងគេង គឺយើងគេងលក់ គឺយើងអត់ដឹងខ្លួនទេ ក៏ប៉ុន្តែក្មេងប្រុសម្នាក់នោះ គាត់ប្រហែលជាគិតរឿងផ្សេងៗច្រើនពេកពីថ្ងៃ ឬក៏គាត់បានមើលអ្វីផ្សេងៗ ដូច្នេះវាធ្វើឲ្យគាត់យល់សប្តិឃើញយក្ស។ អញ្ចឹងនៅពេលដែលគាត់កំពុងតែគេងលក់នោះ គឺធ្វើឲ្យគាត់យល់សប្តិឃើញយក្ស ដែលយក្សនោះគឺ យើងឃើញនៅក្នុងនេះ រូបភាពទី ១៦ គឺមានមុខមាត់អាក្រក់ ដែលយក្សនោះគឺមានមុខពណ៌បៃតង ហើយមានចង្កូមពីរវែងៗ លៀនចេញតាមមាត់មក អញ្ចឹងយក្សគឺមានត្រចៀកខុសពីមនុស្សយើង គឺមានមុខមាត់គួរឲ្យខ្លាច ដោយយើងឃើញនៅក្នុងរូបភាពនេះ គឺវាមានមុខពណ៌បៃតង មានត្រចៀកស្រួច ហើយភ្នែករបស់វាគឺធំៗ ចង្កូមវែងៗ ហើយចង្កូមវាគឺលៀនចេញតាមភ្នែក តាមមាត់។ អញ្ចឹងយើងឃើញយក្សគឺមានពាក់មួកមួយ ឬក៏ពាក់មកុដ ដែលជាមកុដសម្រាប់យក្សពាក់ អញ្ចឹងយក្សគឺមានមុខមាត់អាក្រក់ អញ្ចឹងប្រហែលជាគាត់គិតរឿងផ្សេងៗពីថ្ងៃ ដូច្នេះធ្វើឲ្យគាត់យល់សប្តិអាក្រក់ ដោយសារតែយក្សគឺជាមនុស្សអាក្រក់ អញ្ចឹងនៅពេលដែលយល់សប្តិឃើញយក្ស គឺបានន័យថាគាត់កំពុងតែយល់សប្តិអាក្រក់។ ក៏ប៉ុន្តែដោយសារតែគាត់អស់កម្លាំងខ្លាំង និងគាត់ងងុយគេងខ្លាំងពេក ដូច្នេះគាត់មិនបានភ្ញាក់ដឹងខ្លួន ដោយសារតែការយល់សប្តិឃើញយក្សនោះទេ។ អញ្ចឹងគាត់នៅតែបន្តគេងលង់លក់នៅលើគ្រែ នៅក្នុងបន្ទប់គេងរបស់គាត់ ជាបន្តទៀត ទោះបីជាគាត់យល់សប្តិឃើញយក្សក៏ដោយ ក៏គាត់អត់ភ្ញាក់ដែរ។ អញ្ចឹងបានន័យថាក្មេងប្រុសម្នាក់នេះ គឺគាត់អស់កម្លាំងខ្លាំង ដូច្នេះហើយទើបគាត់យល់សប្តិឃើញយក្សក៏គាត់នៅតែបន្តគេង នៅតែបន្តដំណេករបស់គាត់ ឬក៏គាត់គេងបន្តយ៉ាងលង់លក់ យ៉ាងស្កប់ស្កល់។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.